ក្រុមការងារអន្តរក្រសួង
សម្របសម្រួលលើការផ្ទេរ និងការអនុវត្ត
មុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

# របាយការណ៍

## ស្តីពី

## ការចុះសិក្សាស្វែងយល់អំពីស្ថានភាពនៃការអនុវត្តមុខងារគ្រប់គ្រង សំរាម សំណល់រឹងទីប្រជុំជន និងការប្រើប្រាស់កញ្ចប់ថវិកា សេវាអនាម័យបរិស្ថាននៅក្រុង ស្រុកមួយចំនួននៃខេត្តកណ្តាល ស្វាយរៀង ព្រៃវែង កំពង់ស្ពឺ និងកំពត ក្នុងឆ្នាំ២០១៩

# របាយការណ៍
# ស្តីពី
# ការចុះសិក្សាស្វែងយល់អំពីស្ថានភាពនៃការអនុវត្តមុខងារគ្រប់គ្រងសំរាម សំណល់រឹង ទីប្រជុំជន និងការប្រើប្រាស់កញ្ចប់សេវាអនាម័យបរិស្ថាន នៅក្រុង ស្រុកមួយចំនួននៃគោលដៅចំនួន ៥

## ១. សេចក្តីផ្តើម

កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ បានកំណត់ការផ្ទេរមុខងារ និងធនធានពីថ្នាក់ជាតិទៅឱ្យថ្នាក់ក្រោមជាតិ ជាកិច្ចការអាទិភាពមួយដែលត្រូវអនុវត្ត ដើម្បីធានាដល់ការអភិវឌ្ឍមូលដ្ឋាន និងការផ្តល់សេវាសាធារណៈនៅកៀកជិតប្រជាពលរដ្ឋ ប្រកបដោយប្រសិទ្ធភាព បរិយាប័ន្នសង្គម និងមានភាពឆ្លើយតប។

កន្លងមក មុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ត្រូវបានប្រគល់ទៅឱ្យរដ្ឋបាលថ្នាក់រាជធានី ខេត្ត តាមរយៈអនុក្រឹត្យលេខ៣៦ អនក្រ.បក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៩៩ ដែលរដ្ឋបាលរាជធានី ខេត្តនីមួយៗ មានតួនាទី ភារកិច្ច ក្នុងការគ្រប់គ្រង និងដឹកនាំការងារពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។ បន្ទាប់មក ដើម្បីធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន សំដៅធានាបាននូវសោភ័ណភាព កិច្ចគាំពារសុខភាពសាធារណៈ និងបរិស្ថានឱ្យកាន់តែល្អប្រសើរឡើង រាជរដ្ឋាភិបាលបានប្រគល់មុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនទៅឱ្យរដ្ឋបាលរាជធានី និងក្រុង ស្រុក ដែលជារដ្ឋបាលនៅកៀកជិតប្រជាពលរដ្ឋ តាមរយៈអនុក្រឹត្យលេខ១១៣ អនក្រ.បក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។ ទន្ទឹមនេះ រាជរដ្ឋាភិបាលក៏បានបង្កើតឱ្យមានកញ្ចប់ថវិកាសេវាអនាម័យបរិស្ថាន សម្រាប់អនុវត្តមុខងារគ្រប់គ្រងសំរាម សំណល់រឹង រាវតាមទីប្រជុំជន ដែលកញ្ចប់ថវិកានេះបានប្រើប្រាស់សម្រាប់គាំទ្រដល់រដ្ឋបាលក្រុងចំនួន២៦ នៃខេត្តទាំង២៤ ចាប់ពីឆ្នាំ២០១៥ រហូតមកដល់ឆ្នាំ២០២០នេះ។

តាមរយៈការដាក់ចេញនូវអនុក្រឹត្យថ្មីខាងលើនេះ រដ្ឋបាលរាជធានី ក្រុង ស្រុក មានតួនាទី ភារកិច្ច និងការទទួលខុសត្រូវក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ដូចខាងក្រោម៖

- រៀបចំផែនការគ្រប់គ្រង និងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំសម្រាប់ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- រៀបចំ និងអនុវត្តនូវវិធានការសម្រាប់ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន តាមរយៈការដាក់ចេញដីកា ឬលិខិតបទដ្ឋាននានា
- បង្កើត គ្រប់គ្រង និងចាត់ចែងសេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន
- ណែនាំដល់ប្រជាជនអំពីការសម្អាតអនាម័យបរិស្ថាន និងការប្រើប្រាស់សេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនដែលបានរៀបចំនៅក្នុងមូលដ្ឋាន និង
- អប់រំ និងផ្សព្វផ្សាយអំពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ប្រកបដោយសុវត្ថិភាពបរិស្ថាន អំពីកម្មវិធីកាត់បន្ថយការបង្កើត ការប្រើប្រាស់ឡើងវិញ និងការកែច្នៃ និងអំពីការលើកកម្ពស់ការប្រើប្រាស់ផលិតផលដែលបានមកពីការកែច្នៃសំរាម សំណល់រឹងទីប្រជុំជន។

ដើម្បីជានាដល់ការគាំទ្រដល់ការអនុវត្តមុខងារនេះ ក្រុមការងារអន្តរក្រសួងមួយត្រូវបានបង្កើតឡើងដែលមានសមាសភាពទាំងមន្ត្រីជាន់ខ្ពស់ និងមន្ត្រីបច្ចេកទេសមកពីក្រសួងមហាផ្ទៃ ក្រសួងបរិស្ថាន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងលេខាធិការដ្ឋាន គ.ជ.អ.ប ដែលមានបេសកកម្មចម្បងសហការរៀបចំលិខិតបទដ្ឋាន និងគាំទ្រដល់ការអនុវត្តមុខងារគ្រប់គ្រងសំរាម សំណល់រឹងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

គិតមកដល់ពេលនេះ លិខិតបទដ្ឋាន និងគោលការណ៍ណែនាំបច្ចេកទេសមួយចំនួនត្រូវបានដាក់ចេញ និងផ្សព្វផ្សាយដោយក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធនានា រួមមាន៖

- សេចក្តីណែនាំអន្តរក្រសួងលេខ១៤១១ សជណ.បស្ក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការអនុវត្តមុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- គោលការណ៍ណែនាំបច្ចេកទេសស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៦
- ប្រកាសអន្តរក្រសួងលេខ១៩៥ ប្រក.បស្ក ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការកំណត់កម្រៃអតិបរមានៃសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និង
- ប្រកាសអន្តរក្រសួងលេខ៨៦៨២ ប្រក ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៩ ស្តីពីការគ្រប់គ្រង និងការប្រើប្រាស់ចំណូលដែលបានមកពីការពិន័យអន្តការណ៍ ចំពោះអំពើល្មើសនឹងអនុក្រឹត្យស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

ទោះបីលិខិតបទដ្ឋាន និងគោលការណ៍ណែនាំខាងលើបានដាក់ចេញ និងបានធ្វើការផ្សព្វផ្សាយយ៉ាងទូលំទូលាយ ក៏រដ្ឋបាលក្រុង ស្រុកមួយចំនួនអនុវត្តមុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជននៅមិនទាន់បានល្អប្រសើរនៅឡើយ ដោយមូលហេតុកង្វះធនធានហិរញ្ញវត្ថុ ធនធានមនុស្ស និងបច្ចេកទេស។ ទន្ទឹមនោះប្រជាពលរដ្ឋ មិនសូវមានការយល់ដឹង និងចូលរួម ព្រមទាំងកង្វះដៃគូឯកជនវិនិយោគក្នុងការសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម ហើយទីលានចាក់សំរាម មិនទាន់មានគ្រប់គ្រាន់ និងអនុលោមតាមស្តង់ដារគុណភាព ស្របតាមបទដ្ឋានបច្ចេកទេសនៅឡើយ។

ផ្អែកតាមស្ថានភាពនេះ ក្រុមការងារអន្តរក្រសួងដែលមានក្រសួងមហាផ្ទៃ ក្រសួងបរិស្ថាន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងលេខាធិការដ្ឋាន គ.ជ.អ.ប បានចុះសិក្សាស្វែងយល់អំពីស្ថានភាពនៃការអនុវត្តមុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងការប្រើប្រាស់កញ្ចប់ថវិកាសេវាអនាម័យបរិស្ថាន នៅរដ្ឋបាលក្រុង ស្រុកមួយចំនួន។

## ២. គោលបំណងនៃការសិក្សា

ការសិក្សានេះមានគោលបំណងប្រមូលនូវព័ត៌មានទាំងឡាយពាក់ព័ន្ធនឹងការអនុវត្តមុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ជាពិសេសបញ្ហាប្រឈមចម្បងៗរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តមុខងារនេះ ដើម្បីឱ្យក្រុមការងារអន្តរក្រសួងមានមូលដ្ឋាន ក្នុងការពិនិត្យ និងពិភាក្សារៀបចំលិខិតបទដ្ឋាន និងគាំទ្របច្ចេកទេសដល់ការអនុវត្តមុខងារនេះនៅរដ្ឋបាលថ្នាក់ក្រោមជាតិឱ្យកាន់តែមានភាពប្រសើរឡើង។

ការសិក្សានេះបានផ្តោតលើផ្នែកសំខាន់ៗចំនួន៣ រួមមាន៖

១. ស្ថានភាពនៃការគ្រប់គ្រងសំរាម សំណល់រឹងរួមមានការអនុវត្តកិច្ចសន្យាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម និងការគ្រប់គ្រង និងការប្រើប្រាស់ទីលានចាក់សំរាម

២. ស្ថានភាពការប្រើប្រាស់កញ្ចប់ថវិកាសេវាអនាម័យបរិស្ថាន និង

៣. បញ្ហាប្រឈមពាក់ព័ន្ធនឹងការអនុវត្តមុខងារ និងការប្រើប្រាស់កញ្ចប់ថវិកាសេវាអនាម័យបរិស្ថាន។

## ៣. វិធីសាស្ត្រចុះសិក្សាស្វែងយល់

ក្រុមការងារអន្តរក្រសួង បានកំណត់យកក្រុង ស្រុកចំនួន១១នៃខេត្តចំនួន៥ ដើម្បីចុះសិក្សា ដោយក្រុមការងារអន្តរក្រសួងរួមគ្នាចុះសិក្សានៅខេត្តកណ្តាល ដើម្បីធ្វើជាគំរូបទពិសោធន៍ សម្រាប់ការស្វែងយល់អំពីស្ថានភាពជាទូទៅនៃការគ្រប់គ្រងសំរាម សំណល់រឹង ព្រមទាំងដើម្បីកែសម្រួលនូវបញ្ជីសំណួរ សម្រាប់ការចុះសិក្សាបន្ត។ បន្ទាប់មក ក្រុមការងារអន្តរក្រសួង ត្រូវបានបែងចែកជាពីរក្រុម ដែលក្រុមទីមួយចុះទៅសិក្សានៅខេត្តស្វាយរៀង និងខេត្តព្រៃវែង និងក្រុមទីពីរចុះទៅសិក្សានៅខេត្តកំពង់ស្ពឺ និងខេត្តកំពត។

### ក. ក្របខណ្ឌពេលវេលា និងរដ្ឋបាលក្រុង ស្រុកគោលដៅ

- ចាប់ពីថ្ងៃទី០៥ ដល់ថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៩
    - ក្រុងតាខ្មៅ និងស្រុកកៀនស្វាយ នៃខេត្តកណ្តាល
- ចាប់ពីថ្ងៃទី០២ ដល់ថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១៩
    - ក្រុងបាវិត ក្រុងស្វាយរៀង ស្រុកកំពង់រោទិ៍ នៃខេត្តស្វាយរៀង
    - ក្រុងព្រៃវែង និងស្រុកពាមរក៍ នៃខេត្តព្រៃវែង
- ចាប់ពីថ្ងៃទី២៨ ដល់ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៩
    - ក្រុងច្បារមន និងស្រុកឧដុង្គ នៃខេត្តកំពង់ស្ពឺ
    - ក្រុងកំពត និងស្រុកឈូក នៃខេត្តកំពត។

### ខ. សមាសភាពក្រុមការងារអន្តរក្រសួង

យោងតាមសេចក្តីសម្រេចលេខ២១១៣ សសរ របស់ក្រសួងមហាផ្ទៃ ក្រុមការងារអន្តរក្រសួងនេះ ត្រូវដឹកនាំដោយ**ឯកឧត្តម លេង ឌី** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាប្រធានក្រុមការងារអន្តរក្រសួង មានសមាសភាពចូលរួមពីតំណាងក្រសួងមហាផ្ទៃ ក្រសួងបរិស្ថាន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងតំណាងលេខាធិការដ្ឋាន គ.ជ.អ.ប។

ដើម្បីសម្រួលដល់ដំណើរការនៃការចុះសិក្សា ក្រុមការងារអន្តរក្រសួងនេះ ត្រូវបានរៀបចំបែងចែកជា២ក្រុម ដើម្បីចុះសិក្សានៅតាមក្រុង ស្រុកនៃខេត្តគោលដៅ រួមមាន៖

- ក្រុមទី១ ដឹកនាំដោយ **ឯកឧត្តម លេង ឌី** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាប្រធានក្រុមការងារអន្តរក្រសួង ចុះទៅសិក្សានៅខេត្តកណ្តាល(ដឹកនាំរួម) និងនៅខេត្តកំពង់ស្ពឺ និងខេត្តកំពត *(ជូនភ្ជាប់ជាមួយនូវតារាងសមាសភាពក្រុមការងារ និងកម្មវិធីចុះសិក្សា)*
- ក្រុមទី២ ដឹកនាំដោយ **ឯកឧត្តម ចាយ សាមិត្ត** អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន និងជាអនុប្រធានក្រុមការងារអន្តរក្រសួង ចុះទៅសិក្សានៅខេត្តស្វាយរៀង និងខេត្តព្រៃវែង *(ជូនភ្ជាប់ជាមួយនូវតារាងសមាសភាពក្រុមការងារ និងកម្មវិធីចុះសិក្សា)*។

### គ. សមាសភាពចូលរួមពីរដ្ឋបាលថ្នាក់ក្រោមជាតិ

- អភិបាលរងខេត្ត ទទួលបន្ទុកវិស័យបរិស្ថាន
- នាយករដ្ឋបាលខេត្ត

- អភិបាលក្រុង
- ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ប្រធានមន្ទីរបរិស្ថាន
- ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូន
- នាយកទីចាត់ការហិរញ្ញវត្ថុ
- នាយកទីចាត់ការអន្តរវិស័យ និងមន្ត្រីពាក់ព័ន្ធនានា។

## ៤. លទ្ធផលនៃការចុះសិក្សា

ក្រោយការចុះទៅសិក្សា ព្រមទាំងពិភាក្សាយោបល់ជាមួយនឹងតំណាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធនានា ក្រុមការងារអន្តរក្រសួង បានទទួលលទ្ធផលនៃការចុះទៅសិក្សា ដូចខាងក្រោម៖

### ក. ខេត្តកណ្តាល

#### ក.១. ក្រុងតាខ្មៅ

#### ក.១.១. ស្ថានភាពនៃការគ្រប់គ្រងសំរាម សំណល់រឹង

- **កិច្ចសន្យាប្រមូលសំរាម៖** ត្រូវធ្វើឡើងរវាងរដ្ឋបាលខេត្តកណ្តាលជាមួយក្រុមហ៊ុន ឃីម ស៊ុន្នី រយៈពេល២៨ឆ្នាំ ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១២ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០៣៩។ ប៉ុន្តែចាប់ពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៨ កិច្ចសន្យានេះត្រូវបានផ្ទេរឱ្យទៅក្រុមហ៊ុន ស៊ីន ទ្រី ដើម្បីបន្តអនុវត្តកិច្ចសន្យា តាមរយៈលិខិតផ្ទេរសិទ្ធិរបស់ក្រុមហ៊ុន ឃីម ស៊ុន្នី ឱ្យទៅក្រុមហ៊ុន ស៊ីន ទ្រី។ ចាប់ពីពេលនោះមករហូតមកទល់ពេលនេះ រដ្ឋបាលក្រុងពុំទាន់មានការរៀបចំ ពិនិត្យ និងកែសម្រួលកិច្ចសន្យានេះស្របតាមស្មារតីនៃអនុក្រឹត្យ១១៣នៅឡើយ
- **បរិមាណសំរាម៖** នៅឆ្នាំ២០១៩ បរិមាណសំរាមនៅក្នុងក្រុងតាខ្មៅមានប្រមាណ៤០០តោនក្នុងមួយថ្ងៃ
- **ការផ្តល់សេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម៖** ក្រុងតាខ្មៅមាន១០សង្កាត់ តែការសម្អាតប្រមូល និងដឹកជញ្ជូនបានធ្វើតែ៦សង្កាត់ ដែលមានខ្នងផ្ទះ និងទីតាំងអាជីវកម្មចំនួន១៣២៥៩ មានប្រមាណជា៨៤,៥%នៃទីតាំងភូមិសាស្ត្រក្រុងតាខ្មៅទាំងមូល។ ដោយឡែក ការប្រមូលកម្រៃសេវាពីទីតាំងខ្នងផ្ទះ និងទីតាំងបញ្ចេញសំរាម បានត្រឹមតែ៦៤០៩ទីតាំងប៉ុណ្ណោះ គឺស្មើនឹង៤៨,៣៣%នៃចំនួនខ្នងផ្ទះ និងទីតាំងសរុប។ ការកំណត់កម្រៃសេវាប្រមូលសំរាមត្រូវបានអនុវត្តតាមសៀវភៅបន្ទុកចាស់ដែលបានអនុវត្តតាំងពីឆ្នាំ២០១២មកម្ល៉េះ។ បច្ចុប្បន្ន ដោយមានប្រកាសអន្តរក្រសួងលេខ១៩៥ ប្រក.បស្ថ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការកំណត់កម្រៃអតិបរមានៃសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន រដ្ឋបាលក្រុងបានស្នើសុំទៅរដ្ឋបាលខេត្ត ដើម្បីកែសម្រួលថ្លៃសេវាឱ្យស្របតាមស្ថានភាពបច្ចុប្បន្ន ហើយក៏បានទទួលការឯកភាពពីរដ្ឋបាលខេត្ត ប៉ុន្តែ គិតមកដល់ចុងឆ្នាំ២០១៩នេះ រដ្ឋបាលក្រុងពុំទាន់បានដាក់ចេញតារាងកម្រៃសេវាថ្មី ដើម្បីអនុវត្តនៅឡើយទេ

- **ចំណូលរដ្ឋបាលក្រុង៖** មិនធ្លាប់ទទួលបានថវិកាជាចំណូលរបស់ក្រុងពីការបង់ចំណូលរបស់ក្រុមហ៊ុន ឃីម ស៊ុន្នី ឬក្រុមហ៊ុន ស៊ីន ទ្រីទេ
- **ការគាំទ្ររបស់រដ្ឋបាលក្រុង៖** មានមន្ត្រីចំនួន២២នាក់ និងប្រជាការពារនៅតាមសង្កាត់នីមួយៗ ដើម្បីបោសសម្អាត ប្រមូល និងដឹកជញ្ជូនសំរាមនៅតាមសួនច្បារ និងទីសាធារណៈ។ មិនតែប៉ុណ្ណោះ រដ្ឋបាលក្រុងក៏បានទិញ និងប្រគល់រ៉ឺម៉កចំនួន១០សម្រាប់ដឹកជញ្ជូនសំរាមជូនសង្កាត់ទាំង១០នៃក្រុងតាខ្មៅ។ ពាក់ព័ន្ធនឹងការចូលរួមអនុវត្តការងារគ្រប់គ្រងសំរាមនេះ រដ្ឋបាលក្រុងបានប្រតិភូកម្មឱ្យទៅរដ្ឋបាលសង្កាត់លើការងារមួយចំនួនដូចជាការប្រមូលសំរាមតាមផ្លូវលំតូចៗ ដែលក្រុមហ៊ុនមិនអាចទៅដល់ និងសម្របសម្រួលប្រមូលថ្លៃសេវាប្រមូលសំរាមជូនក្រុមហ៊ុន (ក្រុមហ៊ុនទទួលបន្ទុកក្នុងការប្រមូលកម្រៃសេវានៅតាមខ្នងផ្ទះ និងទីតាំងអាជីវកម្ម)។ សង្កាត់នីមួយៗ បានរៀបចំក្រុមប្រជាការពារចំនួន២ក្រុម ដើម្បីប្រមូល និងដឹកជញ្ជូនសំរាម
- **ទីលានចាក់សំរាមបច្ចុប្បន្ន៖** ទីលានចាក់សំរាមមានផ្ទៃដីទំហំប្រហែល២ហិកតា ជាកម្មសិទ្ធិរបស់រដ្ឋបាលខេត្ត ដែលមានចំងាយប្រហែល៥គីឡូម៉ែត្រពីស្រុកស្អាង។ រហូតមកដល់ពេលនេះ ទីលានចាក់សំរាមនេះមិនអាចមានលទ្ធភាពទទួលផ្ទុកសំរាមបានទៀតនោះទេ ដោយសារសំរាមដែលបានចាក់មានកម្ពស់ខ្ពស់ជាងទីលាន ហើយក៏ប៉ះពាល់ដល់ការរស់នៅរបស់ប្រជាពលរដ្ឋផងដែរ
- **ឡដុតសំរាម៖** ក្រសួងបរិស្ថានបានផ្តល់ឡដុតសំរាមស្ងួតចំនួន២ដែលមានសមត្ថភាពដុតសំរាមពី៥ទៅ៨តោនក្នុងមួយថ្ងៃ (កម្រិតមធ្យម) ដោយបានរៀបចំនៅក្រុងតាខ្មៅ និងស្រុកអង្គស្នួល។ ជាមួយគ្នានេះដែរ រដ្ឋបាលខេត្តបានសិក្សាស្រាវជ្រាវ ក្នុងការរៀបចំដាក់ឡដុតសំរាម៣បន្ថែមទៀតនៅក្នុងស្រុកពញាឮ ស្រុកកោះធំ និងស្រុកមុខកំពូល
- **ការគាំទ្ររបស់រដ្ឋបាលខេត្ត៖** បានឧបត្ថម្ភថវិកាជូនរដ្ឋបាលក្រុង ស្រុកនីមួយៗ ចំនួន១ម៉ឺនដុល្លារក្នុងមួយឆ្នាំ សម្រាប់ការគ្រប់គ្រងសំរាម នៅក្នុងដែនសមត្ថកិច្ចរៀងៗខ្លួន។

**ក.១.២. ការប្រើប្រាស់កញ្ចប់ថវិកាសេវាអនាម័យបរិស្ថាន**

- នៅឆ្នាំ២០១៩ រដ្ឋបាលក្រុងតាខ្មៅបានទទួលកញ្ចប់ថវិកាសេវាអនាម័យបរិស្ថានចំនួន៣៦៦លានរៀល
- រដ្ឋបាលក្រុងតាខ្មៅបានប្រើប្រាស់ថវិកានេះលើការផ្សព្វផ្សាយ ទិញមធ្យោបាយដឹកជញ្ជូន និងសំភារៈ ព្រមទាំងឧបត្ថម្ភជូនប្រជាការពារ និងអ្នកស្ម័គ្រចិត្តប្រមូលសំរាមនៅតាមសង្កាត់។

**ក.១.៣. ការរៀបចំផែនការគ្រប់គ្រង និងផែនការសកម្មភាព**

- រដ្ឋបាលក្រុងតាខ្មៅ មិនទាន់បានរៀបចំដាក់ចេញនូវផែនការគ្រប់គ្រង និងផែនការសកម្មភាពសម្រាប់អនុវត្តមុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ដោយសាររដ្ឋបាលក្រុងមិនមានបច្ចេកទេសក្នុងការរៀបចំផែនការគ្រប់គ្រងសំរាម
- រដ្ឋបាលក្រុង មិនទាន់បានរៀបចំ និងដាក់ចេញដីការបស់ខ្លួន ស្តីពីការកំណត់តម្លៃសេវាប្រមូល និងដឹកជញ្ជូនសំរាមនៅតាមខ្នងផ្ទះ និងនៅតាមទីតាំងបញ្ចេញសំរាមផ្សេងៗនៅឡើយទេ ដោយនៅបន្តអនុវត្តតាមសៀវភៅបន្ទុកចាស់ដែលរៀបចំដោយរដ្ឋបាលខេត្ត។

### ក.២. ស្រុកកៀនស្វាយ

#### ក.២.១. ស្ថានភាពនៃការគ្រប់គ្រងសំរាម សំណល់រឹង

- **ការផ្តល់សេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម៖** បច្ចុប្បន្ន រដ្ឋបាលស្រុកកៀនស្វាយ ពុំទាន់បានចុះកិច្ចសន្យាជាមួយក្រុមហ៊ុនវិនិយោគសម្អាត ប្រមូល និងដឹកជញ្ជូនសំរាមនៅឡើយទេ។ សព្វថ្ងៃរដ្ឋបាលស្រុកបានអនុញ្ញាតឱ្យក្រុមហ៊ុន ប៉ោ សេង ផ្តល់សេវានេះនៅទីតាំងរមនីយដ្ឋានកៀនស្វាយ និងនៅទីតាំងជុំវិញផ្សារ។ កន្លងមក ក្រុមហ៊ុន ប៉ោ សេង បានអនុវត្តការងារប្រមូលសំរាមបានល្អប្រសើរ និងមិនមានការកកស្ទះសំរាមនៅក្នុងតំបន់រមនីយដ្ឋាន និងទីផ្សារទេ ប៉ុន្តែ ក្រុមហ៊ុនមិនទាន់បានពង្រីកសេវាប្រមូលសំរាមរបស់ខ្លួននៅតាមភូមិសាស្ត្រដទៃទៀត ក្នុងស្រុកកៀនស្វាយនៅឡើយ
- **ទីលានចាក់សំរាម៖** សំរាមដែលប្រមូលបាន ត្រូវបានដឹកជញ្ជូនយកទៅចាក់ចោលនៅទីលានចាក់សំរាមរួមដែលស្ថិតនៅក្នុងស្រុកស្អាង។ រដ្ឋបាលស្រុកកៀនស្វាយបានស្នើសុំរដ្ឋបាលខេត្តរៀបចំទីលានចាក់សំរាមថ្មីលើផ្ទៃដីដែលបានបម្រុងទុកមានទំហំ៥ហិកតា ដោយសារទីលានចាក់សំរាមបច្ចុប្បន្នមានចំងាយឆ្ងាយពីទីតាំងស្រុក
- **ការគាំទ្ររបស់រដ្ឋបាលស្រុក៖** បានប្រតិភូកម្មការងារប្រមូលសំរាមនៅតាមផ្លូវតូចៗឱ្យទៅរដ្ឋបាលឃុំដោយប្រើប្រាស់កញ្ចប់ថវិកាដែលឧបត្ថម្ភដោយរដ្ឋបាលខេត្ត ដើម្បីគាំទ្រដល់រដ្ឋបាលឃុំ។

#### ក.២.២ ការរៀបចំផែនការគ្រប់គ្រង និងផែនការសកម្មភាព

- រដ្ឋបាលស្រុកកៀនស្វាយ មិនទាន់បានរៀបចំដាក់ចេញនូវផែនការគ្រប់គ្រង និងផែនការសកម្មភាពសម្រាប់អនុវត្តមុខងារគ្រប់គ្រងសំរាម ដោយសាររដ្ឋបាលស្រុកមិនមានបច្ចេកទេសក្នុងការរៀបចំផែនការគ្រប់គ្រងសំរាម
- រដ្ឋបាលស្រុក មិនទាន់បានរៀបចំដីកាកំណត់កម្រៃសេវាគ្រប់គ្រងសំរាមនៅឡើយ ដោយសារតម្លៃសេវាបច្ចុប្បន្នត្រូវបានយកតាមតម្លៃ ដែលក្រុមហ៊ុនចរចាជាមួយនឹងម្ចាស់ទីតាំងបញ្ចេញសំរាម និងប្រជាជនដោយផ្ទាល់។

## ខ. ខេត្តស្វាយរៀង

### ខ.១. ក្រុងស្វាយរៀង

#### ខ.១.១ ស្ថានភាពនៃការគ្រប់គ្រងសំរាម សំណល់រឹង

- **កិច្ចសន្យាប្រមូលសំរាម៖** រដ្ឋបាលក្រុងស្វាយរៀង មិនទាន់បានចុះកិច្ចសន្យាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាមជាមួយក្រុមហ៊ុនណាមួយនៅឡើយទេ។ បច្ចុប្បន្ន ការប្រមូលសំរាមនៅតាមខ្នងផ្ទះ និងទីតាំងបញ្ចេញសំរាមឯកជននានា ត្រូវបានអនុវត្តដោយក្រុមហ៊ុនឯកជន សុភី សម្បត្តិ ពាណិជ្ជ ដោយគ្មានកិច្ចសន្យាជាមួយរដ្ឋបាលក្រុង ហើយកម្រៃសេវាត្រូវបានធ្វើឡើងរវាងក្រុមហ៊ុន និងម្ចាស់ទីតាំងបញ្ចេញសំរាម
- **ទីលានចាក់សំរាម៖** ទីលានចាក់សំរាមមានផ្ទៃដីទំហំ៣ហិកតាក្នុងសង្កាត់ស្វាយរៀង ដែលមានចំងាយ២គីឡូម៉ែត្រពីផ្សារវាលយន្តដែលជាកម្មសិទ្ធិរបស់ក្រុមហ៊ុនឯកជន សុភី សម្បត្តិ ពាណិជ្ជ។ រដ្ឋបាលខេត្តក៏បានត្រៀមដីទំហំ៤ហិកតា សម្រាប់រៀបចំទីលានចាក់សំរាមផងដែរ
- **ការគាំទ្ររបស់រដ្ឋបាលក្រុង៖** បានប្រតិភូកម្មការគ្រប់គ្រងឡដុតសំរាមឱ្យទៅសង្កាត់។

**ខ.១.២ ការប្រើប្រាស់កញ្ចប់ថវិកាសេវាអនាម័យបរិស្ថាន**

- នៅឆ្នាំ២០១៩ រដ្ឋបាលក្រុងបានទទួលកញ្ចប់ថវិកាសេវាអនាម័យបរិស្ថានចំនួន ២៧៦លានរៀល
- រដ្ឋបាលក្រុងស្វាយរៀង បានចុះកិច្ចសន្យាជាមួយក្រុមហ៊ុនឯកជន សុភី សម្បត្តិ ៣ណិដ្ឋ ក្នុងការសម្អាត ប្រមូល និងដឹកជញ្ជូនសំរាមតាមទីសាធារណៈ ដែលមានកម្មករសរុបចំនួន៣០នាក់ និងមានរថយន្តប្រតិបត្តិការដឹកសំរាមប្រចាំថ្ងៃចំនួន៣គ្រឿង។

**ខ.១.៣ ការរៀបចំផែនការគ្រប់គ្រង និងផែនការសកម្មភាព**

- រដ្ឋបាលក្រុងស្វាយរៀង មិនទាន់បានរៀបចំដាក់ចេញនូវផែនការគ្រប់គ្រង និងផែនការសកម្មភាពសម្រាប់អនុវត្តមុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ដោយសាររដ្ឋបាលក្រុងមិនមានបច្ចេកទេសក្នុងការរៀបចំផែនការគ្រប់គ្រងសំរាម
- រដ្ឋបាលក្រុង មិនទាន់បានរៀបចំវេទិកាពិគ្រោះយោបល់ជាមួយនឹងប្រជាជន ស្តីពីការកំណត់តម្លៃសេវាប្រមូល និងដឹកជញ្ជូនសំរាមនៅតាមខ្នងផ្ទះ និងនៅតាមទីតាំងបញ្ចេញសំរាមផ្សេងៗ។

**ខ.២. ក្រុងបាវិត**

**ខ.២.១ ស្ថានភាពនៃការគ្រប់គ្រងសំរាម សំណល់រឹង**

- **កិច្ចសន្យាប្រមូលសំរាម៖** រដ្ឋបាលក្រុងបាវិត មិនទាន់បានចុះកិច្ចសន្យាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាមជាមួយក្រុមហ៊ុនណាមួយនៅឡើយទេ។ បច្ចុប្បន្ន ការប្រមូលសំរាមនៅតាមខ្នងផ្ទះ និងទីតាំងបញ្ចេញសំរាមឯកជននានា ត្រូវបានអនុវត្តដោយក្រុមហ៊ុនឯកជន ហាយប្រីដ ហ្គាប៊ីធ ដោយគ្មានកិច្ចសន្យាជាមួយរដ្ឋបាលក្រុង ហើយកម្រៃសេវាត្រូវបានធ្វើឡើងរវាងក្រុមហ៊ុន និងម្ចាស់ទីតាំងបញ្ចេញសំរាម។ នាពេលថ្មីៗនេះ ក្រុមហ៊ុន ស៊ីន ទ្រី បានដាក់ពាក្យស្នើសុំផ្តល់សេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាមនៅក្នុងក្រុង ហើយពុំទាន់មានការពិនិត្យពិភាក្សាទេ
- **ទីលានចាក់សំរាម៖** ទីលានចាក់សំរាមមានផ្ទៃដីទំហំ៤ហិកតា ក្នុងសង្កាត់ប្រកម្ទេស ដែលមានចំងាយ១០គីឡូម៉ែត្រពីទីប្រជុំជនក្រុងបាវិតដែលជាកម្មសិទ្ធិរបស់ក្រុមហ៊ុនឯកជន ហាយប្រីដ ហ្គាប៊ីធ។ កន្លងមក ធនាគារអភិវឌ្ឍអាស៊ី(ADB) ធ្លាប់បានធ្វើការសិក្សាលើការរៀបចំ និងការគ្រប់គ្រងទីលានចាក់សំរាម
- **ឡដុតសំរាម៖** រដ្ឋបាលក្រុង មានឡដុតសំរាមចំនួន១ ហើយការគ្រប់គ្រង និងការប្រើប្រាស់ឡដុតសំរាមនេះ ត្រូវបានប្រគល់ជូនរដ្ឋបាលសង្កាត់។

**ខ.២.២ ការប្រើប្រាស់កញ្ចប់ថវិកាសេវាអនាម័យបរិស្ថាន**

- នៅឆ្នាំ២០១៩ រដ្ឋបាលក្រុង បានទទួលកញ្ចប់ថវិកាសេវាអនាម័យបរិស្ថានចំនួន២៦២លានរៀល
- រដ្ឋបាលក្រុងបាវិត បានចុះកិច្ចសន្យាជាមួយក្រុមហ៊ុន ហាយប្រីដ ហ្គាប៊ីធ ក្នុងការប្រមូល បោសសម្អាត និងដឹកជញ្ជូនសំរាមនៅតាមសួនច្បារ ទីធ្លាសាធារណៈ នៅតាមដងផ្លូវជាតិ និងផ្លូវសំខាន់ៗ និងកាប់ឆ្ការព្រៃប្រមូល សម្អាត និងដឹកជញ្ជូនសំរាមនៅទីសាធារណៈ ដែលមានកម្មករសរុបចំនួន១២៨នាក់ និងមានរថយន្តដឹកសំរាមប្រចាំថ្ងៃ ចំនួន២២គ្រឿង។

**ខ.២.៣ ការរៀបចំផែនការគ្រប់គ្រង និងផែនការសកម្មភាព**

- រដ្ឋបាលក្រុងបាវិត មិនទាន់បានរៀបចំដាក់ចេញនូវផែនការគ្រប់គ្រង និងផែនការសកម្មភាពសម្រាប់អនុវត្តមុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ដោយសាររដ្ឋបាលក្រុងមិនមានបច្ចេកទេសក្នុងការរៀបចំផែនការគ្រប់គ្រងសំរាម
- រដ្ឋបាលក្រុង មិនទាន់បានរៀបចំវេទិកាពិគ្រោះយោបល់ជាមួយនឹងប្រជាជនស្តីពីការកំណត់តម្លៃសេវាប្រមូល និងដឹកជញ្ជូនសំរាមនៅតាមខ្នងផ្ទះ និងនៅតាមទីតាំងបញ្ចេញសំរាមផ្សេងៗ។

**ខ.៣. ស្រុកកំពង់រោទិ៍**

**ខ.៣.១ ស្ថានភាពនៃការគ្រប់គ្រងសំរាម សំណល់រឹង**

- **កិច្ចសន្យាប្រមូលសំរាម៖** រដ្ឋបាលស្រុក មិនទាន់បានចុះកិច្ចសន្យាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាមជាមួយក្រុមហ៊ុនណាមួយនៅឡើយទេ ប៉ុន្តែរដ្ឋបាលស្រុកបានអនុញ្ញាតឱ្យលោក ពេញ ពេជ្រដារ៉ា ផ្តល់សេវាប្រមូល និងដឹកជញ្ជូនសំរាមនៅក្នុងភូមិសាស្ត្រនៃរដ្ឋបាលស្រុក ក្នុងរយៈពេល៣ឆ្នាំ (២០១៨ ដល់២០២០)ដោយត្រូវផ្តល់សេវាប្រមូល និងដឹកជញ្ជូនសំរាមនៅក្នុងទីប្រជុំជនស្រុក កាស៊ីណូចំនួន៣ និងផ្សារនៅក្នុងតំបន់ជាប់ព្រំដែនកម្ពុជា-វៀតណាមនៃភូមិសាស្ត្រស្រុកផងដែរ។ ប្រជាពលរដ្ឋចំនួន៨៨គ្រួសារក្នុងចំណោម១០៩គ្រួសារ បានប្រើប្រាស់និងបង់ថ្លៃសេវាប្រមូលសំរាមក្នុងទីប្រជុំជនស្រុក ដែលមួយគ្រួសារស្ម័គ្រចិត្តបង់ថ្លៃសេវាចំនួន៨៧០០រៀល។ បច្ចុប្បន្ននេះបរិមាណសំរាមដែលប្រមូលបានមានចំនួនប្រមាណ២ ទៅ២តោនកន្លះ ក្នុងមួយថ្ងៃ
- **ទីលានចាក់សំរាម៖** ទីលានចាក់សំរាមមានផ្ទៃដីទំហំ៣០ម៉ែត្រគុណនឹង៥០ម៉ែត្រ ដែលមានចំងាយ១៥០០ម៉ែត្រពីទីប្រជុំជន ជាកម្មសិទ្ធិរបស់លោក ពេញ ពេជ្រដារ៉ា។ ជាមួយគ្នានេះដែរ រដ្ឋបាលស្រុកបានត្រៀមទីលានចាក់សំរាមបម្រុងមួយទៀតដែលមានទំហំកន្លះហិកតា។ ដើម្បីធានាដល់ការទុកដាក់សំរាមបានយូរអង្វែង រដ្ឋបាលស្រុកគ្រោងស្នើទៅរដ្ឋបាលខេត្ត ពិនិត្យមើលទីតាំងដីមួយកន្លែងទំហំ៥ហិកតាដែលមានចំងាយ១គីឡូម៉ែត្រពីទីប្រជុំជន ដែលបច្ចុប្បន្នជាដីកម្មសិទ្ធិរបស់មន្ទីរកសិកម្ម សម្រាប់ធ្វើជាទីលានចាក់សំរាម។

**ខ.៣.២ ការរៀបចំផែនការគ្រប់គ្រង និងផែនការសកម្មភាព**

- រដ្ឋបាលស្រុកកំពង់រោទិ៍ មិនទាន់បានរៀបចំដាក់ចេញនូវផែនការគ្រប់គ្រង និងផែនការសកម្មភាពសម្រាប់អនុវត្តមុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ដោយសាររដ្ឋបាលស្រុកមិនមានបច្ចេកទេសក្នុងការរៀបចំផែនការគ្រប់គ្រងសំរាម
- រដ្ឋបាលស្រុក បានពិគ្រោះយោបល់ជាមួយនឹងប្រជាជនអំពីការកំណត់តម្លៃសេវាប្រមូល និងដឹកជញ្ជូនសំរាមនៅតាមខ្នងផ្ទះ និងនៅតាមទីតាំងបញ្ចេញសំរាមផ្សេងៗរួចហើយ ប៉ុន្តែរដ្ឋបាលស្រុកនៅមិនទាន់រៀបចំដាក់ចេញនូវដីកាកំណត់តម្លៃសេវាប្រមូល និងដឹកជញ្ជូនសំរាមនៅឡើយទេ។

**គ. ខេត្តព្រៃវែង**

**គ.១ ក្រុងព្រៃវែង**

**គ.១.១ ស្ថានភាពនៃការគ្រប់គ្រងសំរាម សំណល់រឹង**

- **កិច្ចសន្យាប្រមូលសំរាម៖** កន្លងមក នៅក្នុងក្រុងព្រៃវែង មិនមានក្រុមហ៊ុនផ្តល់សេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម ដោយសារមិនមានក្រុមហ៊ុនណាមួយមានបំណងចង់វិនិយោគលើការសម្អាត ប្រមូល និងដឹកជញ្ជូនសំរាមក្នុងក្រុងព្រៃវែង។ ថ្មីៗនេះ រដ្ឋបាលក្រុងបានអនុញ្ញាតឱ្យក្រុមហ៊ុន ស៊ីន ទ្រី ផ្តល់សេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាមនៅក្នុងក្រុងព្រៃវែង ដោយមិនបានអនុវត្តស្របតាមនីតិវិធីលទ្ធកម្មត្រឹមត្រូវទេ
- **ទីលានចាក់សំរាម៖** បច្ចុប្បន្ននេះ ទីលានចាក់សំរាមមានផ្ទៃដីទំហំ២ហិកតា មានទីតាំងនៅក្នុងសង្កាត់បារាយណ៍ ដែលមានចំងាយ៤គីឡូម៉ែត្រពីក្រុង។ ការរៀបចំទីលានចាក់សំរាម និងហេដ្ឋារចនាសម្ព័ន្ធមិនមានលក្ខណៈសមស្របទៅតាមស្តង់ដារអនាម័យបរិស្ថាននៅឡើយទេ
- **ឡដុតសំរាម៖** ក្រសួងបរិស្ថានបានផ្តល់ឡដុតសំរាមស្ទួតចំនួន១ ដែលមានសមត្ថភាពដុតសំរាម ៥តោនក្នុងមួយថ្ងៃ។

**គ.១.២ ការប្រើប្រាស់កញ្ចប់ថវិកាសេវាអនាម័យបរិស្ថាន**

- នៅក្នុងឆ្នាំ២០១៩ រដ្ឋបាលក្រុងបានទទួលកញ្ចប់ថវិកាសេវាអនាម័យបរិស្ថាន ចំនួន២២៥លានរៀល
- រដ្ឋបាលក្រុងព្រៃវែង បានប្រើប្រាស់ថវិកានេះក្នុងការផ្សព្វផ្សាយ ការស្តារលូ និងការសម្អាត ប្រមូល និងដឹកជញ្ជូនសំរាមនៅតាមទីសាធារណៈ និងផ្លូវសំខាន់ៗក្នុងក្រុង ដោយប្រើប្រាស់កម្មករចំនួន ២៣នាក់ ដើម្បីបោសសម្អាតតាមដងផ្លូវសំខាន់ៗចំនួន៨ខ្សែនៅក្នុងក្រុង ដែលមានចំងាយប្រវែង ៣៦៩៥ម៉ែត្រ។

**គ.១.៣ ការរៀបចំផែនការគ្រប់គ្រង និងផែនការសកម្មភាព**

- រដ្ឋបាលក្រុងព្រៃវែង ពុំទាន់មានការរៀបចំផែនការគ្រប់គ្រង និងផែនការសកម្មភាព សម្រាប់អនុវត្តមុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជននៅឡើយទេ ដោយសាររដ្ឋបាលក្រុងមិនមានបច្ចេកទេសក្នុងការរៀបចំផែនការគ្រប់គ្រងសំរាម
- រដ្ឋបាលក្រុងពុំទាន់បានធ្វើការសិក្សាលម្អិតអំពីទិន្នន័យពាក់ព័ន្ធនឹងស្ថានភាពប្រជាជន និងអំពីទីតាំងបញ្ចេញសំរាមនៅឡើយទេ
- រដ្ឋបាលក្រុង មិនទាន់បានរៀបចំវេទិកាពិគ្រោះយោបល់ជាមួយនឹងប្រជាជនស្តីពីការកំណត់តម្លៃសេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាមនៅតាមខ្នងផ្ទះ និងនៅតាមទីតាំងបញ្ចេញសំរាមផ្សេងៗ។

**គ.២ ស្រុកពាមរក៍**

**គ.២.១ ស្ថានភាពនៃការគ្រប់គ្រងសំរាម សំណល់រឹង**

- **កិច្ចសន្យាប្រមូលសំរាម៖** រដ្ឋបាលស្រុកពាមរ៍ មិនទាន់បានចុះកិច្ចសន្យាជាមួយក្រុមហ៊ុនវិនិយោគសម្អាត ប្រមូល និងដឹកជញ្ជូនសំរាមនៅឡើយទេ ក៏ប៉ុន្តែ កន្លងមក រដ្ឋបាលស្រុកបានអនុញ្ញាតឱ្យអ្នកម៉ៅការភាស៊ីតាមផ្សារ ដើម្បីប្រមូល និងដឹកជញ្ជូនសំរាម
- **ទីលានចាក់សំរាម៖** បច្ចុប្បន្ននេះ ទីលានចាក់សំរាមមានផ្ទៃដីទំហំប្រហែល១ហិកតា ដែលជាកម្មសិទ្ធិរបស់អ្នកម៉ៅការភាស៊ីផ្សារ។ ទីលានចាក់សំរាមនេះ មានទំហំតូច មិនទាន់មានលក្ខណៈបច្ចេកទេសអនាម័យបរិស្ថានត្រឹមត្រូវ និងត្រូវលិចទឹកនៅរដូវវស្សា។ សំរាមដែលប្រមូលបានត្រូវបានយកទៅដាក់នៅដេប៉ូផ្ទុកសំរាមបណ្តោះអាសន្នដែលស្ថិតនៅផ្សារអ្នកលឿង តាមបណ្តោយផ្លូវជាតិលេខ១។

**គ.២.២ ការរៀបចំផែនការគ្រប់គ្រង និងផែនការសកម្មភាព**

- រដ្ឋបាលស្រុកពាមរក៍ ពុំទាន់បានរៀបចំផែនការគ្រប់គ្រង និងផែនការសកម្មភាព សម្រាប់អនុវត្តមុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជននៅឡើយទេ ដោយសាររដ្ឋបាលស្រុកមិនមានបច្ចេកទេសក្នុងការរៀបចំផែនការគ្រប់គ្រងសំរាម
- រដ្ឋបាលស្រុកពុំទាន់បានធ្វើការសិក្សាលម្អិតអំពីទិន្នន័យពាក់ព័ន្ធនឹងស្ថានភាពប្រជាជននិងអំពីទីតាំងបញ្ចេញសំរាមនៅឡើយទេ
- រដ្ឋបាលស្រុក មិនទាន់បានរៀបចំវេទិកាពិគ្រោះយោបល់ជាមួយនឹងប្រជាជនស្តីពីការកំណត់តម្លៃសេវាប្រមូល និងដឹកជញ្ជូនសំរាមនៅតាមខ្នងផ្ទះ និងនៅតាមទីតាំងបញ្ចេញសំរាមផ្សេងៗ។

**ឃ .ខេត្តកំពង់ស្ពឺ**

**ឃ ១.ក្រុងច្បារមន**

**ឃ ១.១.ស្ថានភាពនៃការគ្រប់គ្រងសំរាម សំណល់រឹង**

- **កិច្ចសន្យាប្រមូលសំរាម៖** រដ្ឋបាលក្រុងមិនទាន់បានចុះកិច្ចសន្យាជាមួយក្រុមហ៊ុនវិនិយោគក្នុងការសម្អាត ប្រមូល និងដឹកជញ្ជូនសំរាមនៅឡើយទេ ប៉ុន្តែរដ្ឋបាលក្រុងបានអនុញ្ញាតឱ្យក្រុមហ៊ុន វេង សេង គ្រីន សម្អាត ប្រមូល និងដឹកជញ្ជូនសំរាមនៅតាមខ្នងផ្ទះ និងទីតាំងបញ្ចេញសំរាមនានាក្នុងទីប្រជុំជនក្រុង
- **ទីលានចាក់សំរាម៖** បច្ចុប្បន្ននេះ ទីលានចាក់សំរាមមានផ្ទៃដីទំហំ១០ហិកតា និងមានចំងាយពីផ្សារ ៨គីឡូម៉ែត្រ។ ដោយហេតុថា នៅក្បែរទីតាំងទីលានចាក់សំរាមនោះ មានកីឡដ្ឋាន បូរី និងអង្គភាពរដ្ឋមួយចំនួន ទើបរដ្ឋបាលខេត្តពិចារណា និងគ្រោងរកទីលានចាក់សំរាមថ្មី ដែលមានចំងាយឆ្ងាយពីទីប្រជុំជន។ ទីលានចាក់សំរាមថ្មីដែលរដ្ឋបាលខេត្តកំពុងតែធ្វើការសិក្សា គឺមានផ្ទៃដីទំហំ៥០ហិកតានៅក្នុងស្រុកឱរ៉ាល់ ហើយទីលាននោះស្ថិតនៅក្រោមកម្មសិទ្ធិរបស់មន្ទីរបរិស្ថាន។ មិនតែប៉ុណ្ណោះ រដ្ឋបាលខេត្ត គ្រោងនឹងបង្កើតកន្លែងចាក់សំរាម៣កន្លែងផ្សេងទៀត ដែលស្ថិតនៅ៣តំបន់រួមមាន៖ តំបន់ទី១ សម្រាប់ស្រុកបសេដ្ឋ និងស្រុកគងពិសី តំបន់ទី២ សម្រាប់ស្រុកឱរ៉ាល់ ស្រុកឧដុង្គ និងស្រុកថ្ពង និងតំបន់ទី៣ សម្រាប់ក្រុងច្បារមន និងស្រុកភ្នំស្រួច
- **ការគាំទ្ររបស់រដ្ឋបាលខេត្ត៖** រដ្ឋបាលខេត្ត បានបង្កើតក្រុមការងារអភិវឌ្ឍបៃតងដែលទ្រទ្រង់ដោយមូលនិធិអភិវឌ្ឍបៃតង មានតួនាទីជួយសម្រួលដល់ការប្រមូល និងការវេចខ្ចប់សំរាម។ មូលនិធិអភិវឌ្ឍបៃតងនេះ បានចំណូលពីការបង់វិភាគទានរបស់រោងចក្រ សហគ្រាសសរុបប្រមាណ១០% ប៉ុណ្ណោះនៃរោងចក្រ សហគ្រាសទាំងអស់ដែលមានទីតាំងក្នុងភូមិសាស្ត្រនៃខេត្តកំពង់ស្ពឺ (តាមរយៈកិច្ចសន្យាគាំពារបរិស្ថានដែលរោងចក្រ សហគ្រាស មួយចំនួនបានចុះជាមួយនឹងរដ្ឋបាលខេត្ត)។

**ឃ ១.២. ការប្រើប្រាស់កញ្ចប់ថវិកាសេវាអនាម័យបរិស្ថាន**

- នៅឆ្នាំ២០១៩ រដ្ឋបាលក្រុងបានទទួលកញ្ចប់ថវិកាសេវាអនាម័យបរិស្ថាន ចំនួន២៨៣លានរៀល
- រដ្ឋបាលក្រុងច្បារមន បានចុះកិច្ចសន្យាជាមួយក្រុមហ៊ុន វេង សេង គ្រីន ក្នុងការសម្អាត ប្រមូល និងដឹកជញ្ជូនសំរាមនៅទីសាធារណៈ

- រដ្ឋបាលក្រុង បានប្រើប្រាស់កញ្ចប់ថវិកានេះ ដើម្បីផ្សព្វផ្សាយលិខិតបទដ្ឋាន និងខ្លឹមសារអប់រំនានាពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ការបោសសម្អាតតាមដងផ្លូវចំនួន១៣ក្នុងក្រុង និងតាមដងផ្លូវជាតិ និងការស្តារ និងសម្អាតលូ។

**ឃ.១.៣ ការរៀបចំផែនការគ្រប់គ្រង និងផែនការសកម្មភាព**

- រដ្ឋបាលក្រុងច្បារមនមិនទាន់បានរៀបចំដាក់ចេញនូវផែនការគ្រប់គ្រងនិងផែនការសកម្មភាពសម្រាប់អនុវត្តមុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ដោយសាររដ្ឋបាលក្រុងមិនមានបច្ចេកទេសក្នុងការរៀបចំផែនការគ្រប់គ្រងសំរាម
- រដ្ឋបាលក្រុង មិនទាន់បានរៀបចំវេទិកាពិគ្រោះយោបល់ជាមួយនឹងប្រជាជនស្តីពីការកំណត់តម្លៃសេវាប្រមូល និងដឹកជញ្ជូនសំរាមនៅតាមខ្នងផ្ទះ និងនៅតាមទីតាំងបញ្ចេញសំរាមផ្សេងៗ។

**ឃ ២.ស្រុកឧដុង្គ**

**ឃ ១.២.ស្ថានភាពនៃការគ្រប់គ្រងសំរាម សំណល់រឹង**

- **កិច្ចសន្យាប្រមូលសំរាម៖** រដ្ឋបាលស្រុក មិនទាន់បានចុះកិច្ចសន្យាជាមួយក្រុមហ៊ុនវិនិយោគ ក្នុងសម្អាត ប្រមូល និងដឹកជញ្ជូនសំរាមនៅឡើយទេ។ ក៏ប៉ុន្តែ កន្លងមក រដ្ឋបាលស្រុកបានអនុញ្ញាតឱ្យអ្នកម៉ៅការភាស៊ីផ្សារប្រមូល និងដឹកជញ្ជូនសំរាមចេញពីទីតាំងផ្សារ ទីតាំងជុំវិញផ្សារ និងខ្នងផ្ទះរបស់ប្រជាជនដែលស្ថិតនៅតាមដងផ្លូវជាតិតែប៉ុណ្ណោះ នៅក្នុងឃុំបីនៃស្រុកឧដុង្គរួមមាន ឃុំវាំងចាស់ ឃុំក្សេមក្សាន្ត និងឃុំក្រាំងចេក។ កម្រៃសេវាប្រមូលសំរាម ត្រូវបានកំណត់តាមរយៈការព្រមព្រៀងគ្នារវាងម្ចាស់ទីតាំង និងអ្នកម៉ៅការភាស៊ីផ្សារ
- **ទីលានចាក់សំរាម៖** បច្ចុប្បន្ននេះ ទីលានចាក់សំរាមមានផ្ទៃដីទំហំ៥០ម៉ែត្រគុណា៣០ម៉ែត្រជាកម្មសិទ្ធិឯកជនរបស់អ្នកម៉ៅការភាស៊ីផ្សារ ដែលមានចំងាយ១គីឡូម៉ែត្រពីទីប្រជុំជនស្រុក។ ទីលានចាក់សំរាមនេះ មានទំហំតូចដែលមិនអាចផ្ទុកសំរាមបន្ថែមទៀតបានទេ។ ពាក់ព័ន្ធនឹងបញ្ហានេះ រដ្ឋបាលស្រុក ក៏បានស្នើសុំដី ដែលមានទំហំ១០ហិកតាស្ថិតនៅក្នុងឃុំក្សេមក្សាន្ត និងមានចំងាយ១២គីឡូម៉ែត្រពីទីប្រជុំជនទៅរដ្ឋបាលខេត្ត ដើម្បីធ្វើជាទីលានចាក់សំរាម។ សព្វថ្ងៃ ដីដែលត្រូវបានស្នើសុំនេះ គឺជាកម្មសិទ្ធិរបស់រដ្ឋបាលព្រៃឈើ
- **ការគាំទ្ររបស់រដ្ឋបាលឃុំ៖** រដ្ឋបាលឃុំវាំងចាស់ បានធ្វើការណែនាំដល់ប្រជាជនដែលយកសំរាមមកចោលក្នុងដីទំនេរ ឬចោលពាសវាលពាសកាល។ ដោយឡែក រដ្ឋបាលឃុំក្សេមក្សាន្ត បានដឹកនាំសិស្សនៅវិទ្យាល័យបាត់ដឹង ដើរប្រមូលសំរាមនៅតាមដងផ្លូវជាតិលេខ៥១។

**ឃ ២.២.ការរៀបចំផែនការគ្រប់គ្រង និងផែនការសកម្មភាព**

- រដ្ឋបាលស្រុកឧដុង្គ មិនទាន់បានរៀបចំដាក់ចេញនូវផែនការគ្រប់គ្រង និងផែនការសកម្មភាពសម្រាប់អនុវត្តមុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ដោយសាររដ្ឋបាលស្រុកមិនមានបច្ចេកទេសក្នុងការរៀបចំផែនការគ្រប់គ្រងសំរាម
- រដ្ឋបាលស្រុក មិនទាន់បានរៀបចំវេទិកាពិគ្រោះយោបល់ជាមួយនឹងប្រជាជនស្តីពីការកំណត់តម្លៃសេវាប្រមូល និងដឹកជញ្ជូនសំរាមនៅតាមខ្នងផ្ទះនិងនៅតាមទីតាំងបញ្ចេញសំរាមផ្សេងៗ។

## ១ .ខេត្តកំពត

### ១ ១.ក្រុងកំពត

#### ១ ១.១.ស្ថានភាពនៃការគ្រប់គ្រងសំរាម សំណល់រឹង

- **កិច្ចសន្យាប្រមូលសំរាម៖** រដ្ឋបាលក្រុង មិនទាន់បានចុះកិច្ចសន្យាជាមួយក្រុមហ៊ុនវិនិយោគ ក្នុងការសម្អាត ប្រមូល និងដឹកជញ្ជូនសំរាមនៅឡើយទេ។ កន្លងមក រដ្ឋបាលខេត្តបានចុះកិច្ចសន្យាជាមួយក្រុមហ៊ុន ឃឹម សោភ័ណ្ឌ ក្នុងរយៈពេល១៦ឆ្នាំ រួចមកក្រុមហ៊ុន ឃឹម សោភ័ណ្ឌបានផ្ទេរសិទ្ធិឱ្យទៅក្រុមហ៊ុន GAEA ដើម្បីបន្តការផ្តល់សេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាមនៅក្នុងក្រុងកំពតដែលត្រូវផុតអាណត្តិនៅដើមឆ្នាំ២០១៩នេះ
- **ចំណូលរដ្ឋបាលក្រុង៖** មិនធ្លាប់ទទួលបានថវិកាជាចំណូលរបស់ក្រុង ពីការបង់ចំណូលរបស់ក្រុមហ៊ុន ឃឹម សោភ័ណ្ឌ ឬក្រុមហ៊ុន GAEAទេ
- **ទីលានចាក់សំរាម៖** បច្ចុប្បន្ននេះ ទីលានចាក់សំរាមមានផ្ទៃដីទំហំ៤ហិកតាជាកម្មសិទ្ធិរបស់ក្រុមហ៊ុន GAEA និងត្រូវបានពង្រីកបន្ថែមចំនួន២ហិកតាទៀត ដើម្បីទទួលទុកសំរាមដែលមានកើនឡើងជាប្រចាំថ្ងៃ។ ដោយឡែក ថ្មីៗនេះ រដ្ឋបាលខេត្តក៏បានគ្រោងរៀបចំទីលានចាក់សំរាមមួយកន្លែង ដែលមានទំហំ១៤,៧ហិកតា ដែលស្ថិតនៅឃុំថ្មី ស្រុកទឹកឈូ ចំងាយ១០គីឡូម៉ែត្រពីក្រុង។ ទីតាំងថ្មីនេះត្រូវបានគ្រោងសម្រាប់ការរៀបចំ និងបំពាក់សំភារៈឱ្យមានលក្ខណៈស្តង់ដារអនាម័យបរិស្ថាន ក្រោមការជួយគាំទ្រ និងឧបត្ថម្ភពីធនាគារអភិវឌ្ឍន៍អាស៊ី( ADB)
- **បរិមាណសំរាម៖** នៅឆ្នាំ២០១៩ បរិមាណសំរាមដែលត្រូវបានបញ្ចេញពីខ្នងផ្ទះ និងទីតាំងអាជីវកម្មនានា មានចំនួន៦៥តោន ក្នុងមួយថ្ងៃ។

#### ១ ២.១.ការប្រើប្រាស់កញ្ចប់ថវិកាសេវាអនាម័យបរិស្ថាន

- នៅក្នុងឆ្នាំ២០១៩នេះ រដ្ឋបាលក្រុង បានទទួលកញ្ចប់ថវិកាសេវាអនាម័យបរិស្ថានចំនួន២៥៣លានរៀល
- រដ្ឋបាលក្រុងកំពត បានចុះកិច្ចសន្យាជាមួយនឹងអង្គភាពអភិរក្សធនធានធម្មជាតិ និងអភិវឌ្ឍ ដើម្បីផ្តល់សិទ្ធិក្នុងការសម្អាត ប្រមូល និងដឹកជញ្ជូនសំរាមនៅតាមទីសាធារណៈ ដងផ្លូវ ចិញ្ចើមផ្លូវសាធារណៈ និងនៅតាមដងព្រែក។ រដ្ឋបាលក្រុងបានប្រើប្រាស់កញ្ចប់ថវិកាសេវាអនាម័យបរិស្ថាននេះ ក្នុងការផ្សព្វផ្សាយអប់រំអំពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ការបោសសម្អាតដងផ្លូវចំនួន១៣ក្នុងក្រុង និងដងផ្លូវជាតិ និងការស្តារ និងសម្អាតលូ
- រដ្ឋបាលក្រុង បានប្រើប្រាស់កម្មករចំនួន៣៣នាក់ ដែលត្រូវបានពង្រាយនៅតាមសង្កាត់ចំនួន៤រួមមាន ក្នុងសង្កាត់កំពង់បាយ ចំនួន៧នាក់ ក្នុងសង្កាត់កំពង់កណ្តាល ចំនួន៧នាក់ ក្នុងសង្កាត់អណ្តូងខ្មែរ ចំនួន៧នាក់ ក្នុងសង្កាត់ក្រាំងអំពិល ចំនួន៧នាក់ និងការបោសសម្អាតនៅតាមបណ្តាយព្រែកចំនួន៥នាក់។

ខ ៣.១.**ការរៀបចំផែនការគ្រប់គ្រង និងផែនការសកម្មភាព**

- រដ្ឋបាលក្រុងកំពត មិនទាន់បានរៀបចំដាក់ចេញនូវផែនការគ្រប់គ្រង និងផែនការសកម្មភាព សម្រាប់អនុវត្តមុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ដោយសាររដ្ឋបាលក្រុងមិនមានបច្ចេកទេសក្នុងការរៀបចំផែនការគ្រប់គ្រងសំរាម
- រដ្ឋបាលក្រុង មិនទាន់បានរៀបចំវេទិកាពិគ្រោះយោបល់ជាមួយនឹងប្រជាជនស្តីពីការកំណត់តម្លៃសេវាប្រមូល និងដឹកជញ្ជូនសំរាមនៅតាមខ្នងផ្ទះ និងនៅតាមទីតាំងបញ្ចេញសំរាមផ្សេងៗ។

ខ ២.**ស្រុកឈូក**

ខ ១.២.**ស្ថានភាពនៃការគ្រប់គ្រងសំរាម សំណល់រឹង**

- **កិច្ចសន្យាប្រមូលសំរាម៖** រដ្ឋបាលស្រុក មិនទាន់បានចុះកិច្ចសន្យាជាមួយក្រុមហ៊ុនវិនិយោគ ក្នុងការសម្អាត ប្រមូល និងដឹកជញ្ជូនសំរាមនៅឡើយទេ។ រដ្ឋបាលស្រុក បានអនុញ្ញាតឱ្យអ្នកម៉ៅការភាស៊ីផ្សារ ជាអ្នកប្រមូល និងដឹកជញ្ជូនសំរាមចេញពីផ្សារ និងទីតាំងផ្ទះប្រជាជននៅជុំវិញផ្សារ ប្រមូល និងដឹកជញ្ជូនសំរាមទៅចោលនៅទីលានចាក់សំរាម ដោយប្រើប្រាស់រថយន្តដឹកសំរាមចំនួន២ និងកម្មករចំនួន៦នាក់។ ថ្លៃសេវាប្រមូលសំរាមពីខ្នងផ្ទះ និងទីបញ្ចេញសំរាមផ្សេងៗ មានចំនួនចាប់ពី ៥០០០រៀលដល់១០០០០រៀល។ រដ្ឋបាលស្រុក បានរៀបចំបង្កើតដេប៉ូទុកដាក់សំរាមចំនួន៥កន្លែងនៅតំបន់ទីប្រជុំជន
- **ទីលានចាក់សំរាម៖** ទីលានចាក់សំរាមបច្ចុប្បន្ននេះ មានផ្ទៃដីទំហំចំនួន៤ហិកតា ជាកម្មសិទ្ធិឯកជនរបស់អ្នកម៉ៅការភាស៊ីផ្សារ ដែលស្ថិតនៅចម្ងាយ៦គីឡូម៉ែតពីទីប្រជុំជន។

ខ ២.២.**ការរៀបចំផែនការគ្រប់គ្រង និងផែនការសកម្មភាព**

- រដ្ឋបាលស្រុកឈូក មិនទាន់បានរៀបចំដាក់ចេញនូវផែនការគ្រប់គ្រង និងផែនការសកម្មភាព សម្រាប់អនុវត្តមុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ដោយសាររដ្ឋបាលស្រុកមិនមានបច្ចេកទេសក្នុងការរៀបចំផែនការគ្រប់គ្រងសំរាម
- រដ្ឋបាលស្រុក មិនទាន់បានរៀបចំវេទិកាពិគ្រោះយោបល់ជាមួយនឹងប្រជាជនស្តីពីការកំណត់តម្លៃសេវាប្រមូល និងដឹកជញ្ជូនសំរាមនៅតាមខ្នងផ្ទះ និងនៅតាមទីតាំងបញ្ចេញសំរាមផ្សេងៗ។

## ៥. សំណូមពររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

ក្នុងអំឡុងពេលនៃការចុះសិក្សាស្វែងយល់អំពីស្ថានភាពនៃការអនុវត្តមុខងារសំរាម សំណល់រឹង ទីប្រជុំជន និងការប្រើប្រាស់កញ្ចប់ថវិកាសេវាអនាម័យបរិស្ថាននៅក្រុង ស្រុកទាំង១១នៃខេត្តទាំង៥ រដ្ឋបាលថ្នាក់ក្រោមជាតិគោលដៅទាំងនោះ បានលើកឡើងនូវសំណូមពរមួយចំនួន ដូចខាងក្រោម៖

- រដ្ឋបាលខេត្ត ក្រុង ស្រុកស្នើសុំការជួយគាំទ្របច្ចេកទេសពីក្រសួង ស្ថាប័ន មន្ទីរបរិស្ថាន និងអង្គភាពជំនាញពាក់ព័ន្ធ ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រ និងផែនការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- រដ្ឋបាលក្រុងស្នើសុំក្រសួងបរិស្ថានបន្តរក្សាទុក និងពិនិត្យលទ្ធភាពបន្ថែមកញ្ចប់ថវិកាសេវាអនាម័យបរិស្ថានជូនរដ្ឋបាលក្រុង ដោយសារបច្ចុប្បន្ននេះ រដ្ឋបាលក្រុងមិនទាន់មានថវិកាពីប្រភពផ្សេងទៀតសម្រាប់គាំទ្រដល់ការអនុវត្តមុខងារនេះនៅឡើយ ហើយម្យ៉ាងទៀតរដ្ឋបាលក្រុងនីមួយៗមានការកើនឡើងនូវចំនួនប្រជាជន ភ្ញៀវទេសចរ និងចរាចរឆ្លងកាត់តំបន់ទីប្រជុំជន

- រដ្ឋបាលស្រុកស្នើសុំក្រសួងបរិស្ថានផ្តល់កញ្ចប់ថវិកាសេវាអនាម័យបរិស្ថាន មកឱ្យរដ្ឋបាលស្រុក ដើម្បីមានលទ្ធភាពអនុវត្តមុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ដោយសារបច្ចុប្បន្ននេះ រដ្ឋបាលស្រុកមិនមានថវិកាសម្រាប់អនុវត្តកិច្ចការសម្អាត ប្រមូល ដឹកជញ្ជូន អប់រំផ្សព្វផ្សាយ និងស្តារប្រព័ន្ធលូ នៅតាមដងផ្លូវជាតិ និងផ្លូវសំខាន់ៗនៅក្នុងទីរួមស្រុកឡើយ
- រដ្ឋបាលក្រុង ស្រុកស្នើសុំរដ្ឋបាលខេត្តសាមីនីមួយៗជួយសម្របសម្រួលជាមួយក្រសួង ស្ថាប័ន និងមន្ទីរ អង្គភាពពាក់ព័ន្ធ ដើម្បីរកទីកន្លែងសមស្របសម្រាប់រៀបចំទីលានចាក់សំរាម និងការគាំទ្រផ្នែកបច្ចេកទេសក្នុងការរៀបចំទីលានដែលមានស្តង់ដារអនាម័យត្រឹមត្រូវ
- រដ្ឋបាលក្រុង ស្រុកស្នើសុំឱ្យមានការផ្តល់ឡដុតសំរាមសម្រាប់ប្រើប្រាស់នៅក្នុងតំបន់ ដែលមិនមានទីលានចាក់សំរាម
- រដ្ឋបាលក្រុង ស្រុកស្នើសុំផ្តល់មធ្យោបាយដឹកជញ្ជូនសំរាមដូចជា រថយន្ត និងរ៉ឺម៉កដឹកសំរាម សម្រាប់ប្រើប្រាស់ក្នុងភូមិសាស្ត្រក្រុង ស្រុកដែលមិនមានក្រុមហ៊ុនដឹកជញ្ជូនសំរាម។

## ៦. សន្និដ្ឋាន

តាមរយៈការចុះសិក្សាស្វែងយល់អំពីការអនុវត្តមុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជននៅរដ្ឋបាលក្រុង ស្រុកចំនួន១១ នៃខេត្តទាំង៥ ក្រុមការងារអន្តរក្រសួងបានពិនិត្យឃើញថា រដ្ឋបាលខេត្ត និងរដ្ឋបាលក្រុង ស្រុកបានខិតខំជំរុញ និងអនុវត្តមុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជននេះយ៉ាងសកម្ម និងទទួលបានលទ្ធផលមួយចំនួនគួរឱ្យកត់សម្គាល់។ ទោះជាយ៉ាងណាក៏ដោយ រដ្ឋបាលថ្នាក់ក្រោមជាតិបានជួបប្រទះនូវបញ្ហាជាច្រើន ដែលធ្វើឱ្យការអនុវត្តមុខងារនេះ មិនទាន់បានរលូនល្អ និងស្របតាមគោលបំណងនៃស្មារតីអនុក្រឹត្យស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជននៅឡើយ។ បញ្ហាទាំងនោះរួមមានដូចជា ការខ្វះខាតធនធានថវិកា និងធនធានមនុស្ស ការគាំទ្រផ្នែកបច្ចេកទេសពីអ្នកពាក់ព័ន្ធនៅមានកម្រិត និងការចូលរួមពីប្រជាពលរដ្ឋមិនទាន់បានពេញលេញ។

ជាងនេះទៅទៀត នៅក្នុងដំណើរការអនុវត្តមុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនទាំងនេះ ក្រុមការងារអន្តរក្រសួងបានរកឃើញនូវបញ្ហាប្រឈមមួយចំនួន ដែលរួមមានៈ

- រដ្ឋបាលក្រុង ស្រុក មិនទាន់បានរៀបចំនូវផែនការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងមិនទាន់បានរៀបចំដាក់ចេញនូវដីកាកំណត់ថ្លៃសេវាប្រមូលដឹកជញ្ជូនសំរាម ព្រមទាំងមិនទាន់បានអនុវត្តការពិន័យអន្តរការណ៍ចំពោះប្រជាពលរដ្ឋ ឬម្ចាស់ទីតាំងបញ្ចេញសំរាមនានាដែលទុកដាក់សំរាមមិនបានត្រឹមត្រូវ
- រដ្ឋបាលក្រុង ស្រុកមួយចំនួន មិនអាចរកដៃគូឬក្រុមហ៊ុនឯកជនវិនិយោគ ក្នុងការសម្អាត ប្រមូល និងដឹកជញ្ជូនសំរាមនៅក្នុងភូមិសាស្ត្ររបស់ខ្លួនបានទេ ដោយសារចំនួនអ្នកប្រើប្រាស់សេវាតិច ប្រជាពលរដ្ឋមិនបានចូលរួមបង់ថ្លៃសេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម និងមិនមានទីតាំងសមស្របសម្រាប់ធ្វើជាទីលានចាក់សំរាម
- រដ្ឋបាលក្រុង ស្រុក ដែលមានក្រុមហ៊ុនសម្អាត ប្រមូល និងដឹកជញ្ជូនសំរាមនៅក្នុងមូលដ្ឋានរបស់ខ្លួន មិនអាចគ្រប់គ្រងអំពីស្ថានភាពចំណូល និងការចំណាយរបស់ក្រុមហ៊ុនទាំងនោះបានទេ ដោយសារការយកកម្រៃសេវាពីប្រជាពលរដ្ឋ និងម្ចាស់ទីតាំងបញ្ចេញសំរាមធ្វើឡើងតាមការព្រមព្រៀងគ្នារវាងក្រុមហ៊ុន និងប្រជាពលរដ្ឋ ឬម្ចាស់ទីតាំងបញ្ចេញសំរាមនោះតែប៉ុណ្ណោះ។ កត្តានេះធ្វើឱ្យរដ្ឋបាល

ក្រុង ស្រុកមិនអាចធ្វើអន្តរាគមន៍ទៅលើគុណភាពនៃការសម្អាត ប្រមូល និងដឹកជញ្ជូនសំរាមរបស់ក្រុមហ៊ុននៅពេលដែលមានការតវ៉ាពីប្រជាពលរដ្ឋ

- ការគាំទ្របច្ចេកទេសពីមន្ទីរបរិស្ថាន និងអ្នកពាក់ព័ន្ធនានាទៅដល់រដ្ឋបាលក្រុង ស្រុកក្នុងការអនុវត្តមុខងារការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជននៅមានកម្រិតទាំងការរៀបចំផែនការ ការសិក្សាប្រមូលទិន្នន័យសំរាម ការស្វែងរកដៃគូសម្រាប់ប្រមូល និងដឹកជញ្ជូនសំរាម និងការរៀបចំទីលានជាដើម
- រដ្ឋបាលក្រុង ស្រុក មិនមានអង្គភាព និងមន្ត្រីច្បាស់លាស់ សម្រាប់ទទួលបន្ទុកលើការងារគ្រប់គ្រងសំរាម សំណល់រឹងរបស់រដ្ឋបាលក្រុង ស្រុក
- រដ្ឋបាលក្រុងភាគច្រើន ពឹងផ្អែកលើកញ្ចប់ថវិកាសេវាអនាម័យបរិស្ថាន ដើម្បីទិញធុងសំរាម សម្អាតប្រមូល និងដឹកជញ្ជូនសំរាមនៅតាមដងផ្លូវ និងទីធ្លាសាធារណៈ ដូសដុល និងស្តារលូ
- ទីលានចាក់សំរាមដែលកំពុងប្រើប្រាស់ភាគច្រើននៅក្រុង ស្រុក គឺជាទីលានកម្មសិទ្ធិឯកជនដោយសាររដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលខេត្តមិនបានបម្រុងទុកដីសម្រាប់ធ្វើទីលានចាក់សំរាម ហើយទីលានទាំងនោះក៏មិនមានលក្ខណៈសមស្របតាមស្តង់ដារអនាម័យបរិស្ថានដែរ។

## ៧. អនុសាសន៍

ដើម្បីដោះស្រាយនូវបញ្ហាប្រឈមដែលបានរកឃើញនៅក្នុងការចុះសិក្សានេះ ចាំបាច់ត្រូវមានការណែនាំមួយចំនួនដល់រដ្ឋបាលថ្នាក់ក្រោមជាតិលើការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ដូចខាងក្រោម៖

- រដ្ឋបាលខេត្ត ដែលមិនទាន់បានផ្ទេរមុខងារគ្រប់គ្រងសំរាម សំណល់រឹងឱ្យទៅរដ្ឋបាលក្រុង ស្រុក ត្រូវសម្របសម្រួលផ្ទេរកិច្ចសន្យាប្រមូលសំរាមនេះ និងការគ្រប់គ្រងផ្សេងៗទៀតឱ្យមករដ្ឋបាលក្រុង ស្រុកជាអ្នកចុះកិច្ចសន្យាផ្ទាល់ជាមួយនឹងក្រុមហ៊ុនប្រមូលសំរាមឱ្យស្របតាមស្មារតីនៃអនុក្រឹត្យលេខ១១៣ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- រដ្ឋបាលខេត្ត និងមន្ទីរបរិស្ថាន ព្រមទាំងអ្នកពាក់ព័ន្ធនានា ត្រូវផ្តល់ការគាំទ្រផ្នែកបច្ចេកទេស និងធនធានដល់រដ្ឋបាលក្រុង ស្រុក ដើម្បីផ្តល់លទ្ធភាពក្នុងការអនុវត្តមុខងារនេះឱ្យកាន់តែល្អប្រសើរឡើង ពិសេសជម្រុញឱ្យក្រុង ស្រុករៀបចំផែនការគ្រប់គ្រង និងផែនការសកម្មភាពថវិកាប្រចាំឆ្នាំ ដើម្បីអនុវត្ត
- រដ្ឋបាលខេត្ត និងអង្គភាពពាក់ព័ន្ធ ត្រូវជួយរដ្ឋបាលក្រុង ស្រុកក្នុងការរៀបចំ និងកំណត់ទីតាំងឱ្យបានសមស្របសម្រាប់រៀបចំទីលានចាក់សំរាម ស្របតាមបទដ្ឋានបច្ចេកទេស
- រដ្ឋបាលក្រុង ស្រុក ត្រូវពង្រឹងការទទួលខុសត្រូវក្នុងភាពជាម្ចាស់របស់ខ្លួនតាមការណែនាំរបស់ក្រសួងបរិស្ថាន ក្នុងការអនុវត្តការងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន តាមរយៈការរៀបចំផែនការមេឱ្យបានច្បាស់លាស់ ការរៀបចំគម្រោងថវិកាប្រចាំឆ្នាំសម្រាប់ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជននៅក្នុងកញ្ចប់ថវិការបស់រដ្ឋបាលក្រុង ស្រុក និងការកៀរគរការគាំទ្រពីក្រសួង ស្ថាប័នថ្នាក់ជាតិ សង្គមស៊ីវិល និងផ្នែកឯកជន ព្រមទាំងអ្នកពាក់ព័ន្ធនានា
- រដ្ឋបាលក្រុង ត្រូវរៀបចំផែនការ និងសកម្មភាពឱ្យបានច្បាស់លាស់ ក្នុងការប្រើប្រាស់កញ្ចប់ថវិកាសេវាអនាម័យបរិស្ថានឱ្យចំគោលដៅ និងមានប្រសិទ្ធភាពស្របតាមលិខិតបទដ្ឋាន និងគោលការណ៍ណែនាំរបស់រដ្ឋបាលថ្នាក់ជាតិ និង

– រដ្ឋបាលក្រុង ស្រុក ត្រូវចាត់តាំងមន្ត្រីឱ្យបានច្បាស់លាស់ ដើម្បីទទួលបន្ទុកក្នុងការគ្រប់គ្រងការងារសំរាម សំណល់រឹងទីប្រជុំជនរបស់រដ្ឋបាលក្រុង ស្រុក។

ថ្ងៃព្រហស្បតិ៍ ៥រោច ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៥ ខែវិច្ឆិកា ឆ្នាំ២០២០

**ប្រធានក្រុមការងារអន្តរក្រសួង**

សេខ ទី